**LONG BEACH UNIFIED SCHOOL DISTRICT**

**ក្រសួងអប់រំតំបន់ឡុងប៊ីច**

**ផ្តល់សេវាកម្មអប់រំនៅ LONG BEACH, LAKEWOOD, SIGNAL HILL AND AVALON**

**ការិយាល័យអគ្គនាយកសាលា**

**1515 HUGHES WAY**
**LONG BEACH, CALIFORNIA 90810-1839**
**(562) 997-8242 • FAX (562) 997-8280**


ថ្ងៃទី៣០ខែមេសា ឆ្នាំ២០០៩

សូមជំរាបមកដល់មាតាបិតាឬអ្នកអាណាព្យាបាលសិស្ស៖

សំបុត្រនេះមានន្ទូវព័ត៌មានថ្មីសំខាន់ស្តីអំពីរោគគ្រុនផ្តាសាយជ្រូក (swine flu) ។ នេះគឺជាការព្យាយាមមិនឈប់ឈររបស់យើង ដើម្បីផ្តល់ឲ្យនូវព័ត៌មានថ្មីៗដើម្បីឲ្យសិស្សនិងបុគ្គលិកសាលាទាំងអស់រក្សាសុខភាពឲ្យបានល្អហើយឲ្យមានសុវត្ថិភាព។

មកទល់នឹងពេលនេះ យើងពុំទាន់មានឃើញអ្នកណាម្នាក់កើតរោគគ្រុនជ្រូកនេះនៅឡើយទេនៅក្នុងក្រសួងអប់រំយើង។ ក៏ប៉ុន្តែនៅក្នុងករណីដែលមានរោគគ្រុននេះកើតមានឡើង សូមជ្រាបថាយើងត្រូវអាចបិទទ្វារសាលារៀនក្នុងកំឡុងរយៈពេលមិនព្រៀងទុក។ អាទិភាពរបស់យើងគឺដើម្បីទប់ស្កាត់ទំនាក់ទំនងរវាងបុគ្គលម្នាក់ៗ ដើម្បីបន្ថយភាពចម្លងរោគ និងរារាំងកុំឲ្យរោគនេះរាលដាល។

ការសម្រេចបិទទ្វារសាលារៀននឹងធ្វើឡើងដោយគិតគូហ្មត់ចត់ក្រោមការណែនាំពីក្រសួងសុខាភិបាលក្រុងឡុងប៊ីច ហើយយើងនឹងជូនដំណឹងដល់លោកអ្នកជាបន្ទាន់។ សម្រាប់ពេលបច្ចុប្បន្ននេះ យើងសូមលើកទឹកចិត្តឲ្យគ្រួសារទាំងអស់រៀបចំផែនការទុកជាមុនសម្រាប់ពេលមានអាសន្នកើតឡើង។ បើសិនជាយើងត្រូវបិទទ្វារសាលារៀន កម្មវិធីទាំងអស់នៅសាលារៀន គឺរួមទាំងកម្មវិធីនៅក្រោយម៉ោងសាលាក៏នឹងត្រូវបញ្ឈប់សិនដែរ ដូច្នេះសូមរៀបចំផែនការឲ្យហើយទុកជាមុនសម្រាប់ការថែរក្សាកុមារនៅផ្ទះ។

យើងកំពុងប្រឹងប្រែងអស់ពីសមត្ថិភាពដើម្បីការពារសិស្សានុសិស្សនិងបុគ្គលិករបស់យើង។ ឧទាហរណ៍ ពេទ្យប្រចាំសាលារៀនរបស់យើងទាំងអស់បានទទួលការហ្វឹកហ្វឺនកន្លងមកថ្មីៗនេះពីក្រសួងសុខាភិបាលស្តីអំពីរបៀបធ្វើតែសរកមើលរោគគ្រុនផ្តាសាយ។ យើងសំណូមពរឲ្យលោកអ្នកនៅបន្តប្រព្រឹត្តតាមវិធីបង្ការការពារទាំងឡាយខាងក្រោមនេះតទៅទៀត៖

- ទុកកូនឲ្យនៅផ្ទះបើកូនឈឺ ឬមានរោគសញ្ញាដូចគ្រុនផ្តាសាយ(រួមទាំងក្តៅខ្លួន ឈឺខ្លួនប្រាណ ក្អក និងហៀរសំបោរ។ សូមប្រាប់ឲ្យសាលាដឹងយ៉ាងច្បាស់លាស់អំពីអាការៈជំងឺរបស់កូនលោកអ្នក
- រំលឹកឲ្យកូនលាងដៃជាញឹកញាប់ ហើយឲ្យគ្របមាត់និងច្រមុះឲ្យជិតនៅពេលក្អកនិងពេលកណ្តាស់
- ផ្តាំកូនកុំឲ្យនៅជិតមនុស្សឈឺ គឺឲ្យនៅយ៉ាងតិចចំងាយ៣ហ្វីទពីមនុស្សឈឺ
- កុំផ្អើលឆោឡោហើយអប់រំណែនាំកូនកុំឲ្យមានការភិតភ័យ

ដើម្បីព័ត៌មានក្បោះក្បាយថែមទៀត សូមឡើងទៅគេហទំព័រក្រសួងអប់រំនៅ www.lbschools.net ដែលយើងបានបង្កើតទំព័រមួយពិសេសស្តីតែអំពីរោគគ្រុនជ្រូកនេះប៉ុណ្ណោះ។

សូមអរគុណដល់ការគាំទ្រជាបន្តរបស់លោកអ្នកមកដល់សិស្សានុសិស្សនិងបុគ្គលិកសាលាយើង។ សុខភាពហើយនិងសុវត្ថិភាពរបស់ពួកគេគឺជាអាទិភាពខ្ពស់បំផុតរបស់យើង។

ដោយសេចក្តីស្មោះចំពោះ,

Christopher J. Steinhauser
អគ្គនាយកសាលា